# មគ្គុទ្ទេសក៍សម្រាប់វគ្គសិក្សា

## គោលបំណងនៃវគ្គសិក្សា

សូមស្វាមន៍ចំពោះការរៀនផ្នែកកម្មសិទ្ធិបញ្ញាពីចម្ងាយតាមរយៈប្រព័ន្ធអ៊ិធឺណែត។ វគ្គនេះមានគោលបំណងដូចខាងក្រោម :

- បង្កើនភាពយល់ដឹងជាទស្សនទានសម្រាប់គន្លឹះនៃកម្មសិទ្ធិបញ្ញា ដែលជាចំណុចចាំបាច់ សម្រាប់ការច្នៃប្រឌិតរបស់មនុស្សដើម្បីធ្វើឲ្យរីកចម្រើនផ្នែកសេដ្ឋកិច្ច និង ការអភិវឌ្ឍន៍សង្គមជឿនលឿននិងដើម្បីសម្រួលដល់ពាណិជ្ជកម្មអន្តរជាតិ តាមរយៈការផ្តល់នូវកិច្ចការពារជាពហុភាគី ។

- ពន្យល់នូវអ្វីជាកិច្ចការពាររបស់កម្មសិទ្ធិបញ្ញា។
- បង្ហាញអំពីសិទ្ធិសញ្ញាដែលគ្រប់គ្រងកម្មសិទ្ធិបញ្ញា ។
- ណែនាំនូវសេវាកម្មរបស់អង្គការកម្មសិទ្ធិបញ្ញាពិភពលោក(WIPO) មួយចំនួនដែលជួយដល់ការគ្រប់គ្រង់ និងកិច្ចការពារកម្មសិទ្ធិបញ្ញានៅលើពិភពលោក ។

សូមកុំមានការព្រួយបារម្ភ ប្រសិនបើពាក្យមួយចំនួនណាមួយនោះក្នុងអត្ថបទនៃវគ្គសិក្សានេះ លោក លោកស្រី មិនយល់ ពាក្យទាំងនោះ នឹងត្រូវបានពន្យល់តាមផ្នែកនីមួយៗនៃវគ្គសិក្សានេះ។

កម្រិតនៃវគ្គសិក្សានេះ គឺពិព័ណនាដ៏ល្អប្រសើរសម្រាប់សេចក្តីផ្តើម ក៏ប៉ុន្តែវគ្គសិក្សានេះគឺសំដៅលើបុគ្គលមួយចំនួន ដូចជាលោក លោកស្រីមួយចំនួន ដែលកំពុងធ្វើការនៅក្នុងផ្នែកកម្មសិទ្ធិបញ្ញា ឬក៏មានបំណងធ្វើការក្នុងមជ្ឈដ្ឋានដែលទាក់ទងនឹងការគ្រប់គ្រងវិស័យកម្មសិទ្ធិបញ្ញា ។ វគ្គនេះ អាចនឹងមានប្រយោជន៍សម្រាប់លោក លោកស្រីទាំងអស់ដែលបង្កើតឲ្យមាននូវទម្រង់កម្មសិទ្ធិបញ្ញា ផ្សេងៗជាច្រើន ហើយមានបំណងស្វែងយល់ពីលទ្ធភាពនៃកិច្ចការពារតាមទម្រង់កម្មសិទ្ធិបញ្ញាទាំងនោះ ផងដែរ ។

©WIPO/OMPI

## រចនាសម្ព័ន្ធនៃវគ្គសិក្សា

យើងបានប៉ាន់ប្រមាណជាមធ្យមនូវរយៈពេល ដែលលោក លោកស្រីនឹងចំណាយពេលសិក្សាវគ្គនេះ គឺត្រូវសិក្សាប្រហែល៥០ម៉ោង។ ជាធម្មតា លោក លោកស្រីអាចស្វែងយល់ថាលទ្ធភាពនៃការសិក្សាក្នុងមួយវគ្គចែកជា១០ម៉ោងក្នុងមួយសប្តាហ៍។ ដូច្នេះ លោក លោកស្រីត្រូវរំពឹងទុកថា ការសិក្សារបស់លោក លោកស្រីនឹងចំណាយពេលប្រហែល៥សប្តាហ៍ ក្នុងខណៈដែលសប្តាហ៍ទី៦ ដែលជាសប្តាហ៍ចុងក្រោយ លោក លោកស្រីនឹងមានពេលរៀបចំការប្រលងបញ្ចប់។ យើងបានបែងចែកជាវគ្គម៉ូឌុលផ្សេងៗ ដែលបានបង្ហាញនៅក្នុងគំនូសបង្ហាញទី១។រយៈពេលនៃម៉ូលឌុលនីមួយៗនិងអនុម៉ូលឌុលនឹងបង្ហាញមុនពេលលោក លោកស្រីចាប់ផ្តើមវគ្គសិក្សា គឺដើម្បីជួយសម្រាប់ផែនការនីមួយៗនៃការសិក្សារបស់លោក លោកស្រី ។

©WIPO/OMPI

# គំនូសបង្ហាញ១ : ការបង្ហាញរចនាសម្ពន្ធនៃវគ្គសិក្សា

មគ្គុទេសនៃវគ្គសិក្សា

ផ្នែកទី១

សេចក្តីណែនាំអំពីកម្មសិទ្ធិបញ្ញា

---

សិទ្ធិអ្នកនិពន្ធ

ប្រកាសនីយបត្រតក្កកម្ម

ពាណិជ្ជសញ្ញា

សិទ្ធិប្របហាក់ប្របហែល

គំនូរឧស្សាហកម្ម

ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ

ប្រព័ន្ធចុះបញ្ជីជាលក្ខណៈអន្តរជាតិ
តាមសទ្ធិសញ្ញាក្រោមការគ្រប់គ្រងរបស់អង្គការកម្មសិទ្ធិពិភពលោក

កិច្ចការពារពូជរថ្មីនៃដំណាំ

ការប្រកួតប្រជែងមិនស្មោះត្រង់

ផ្នែកទី២

---

ការពិភាក្សា និង សង្ខេបវគ្គសិក្សា

ផ្នែកទី៣

ការប្រលងបញ្ចប់

©WIPO/OMPI

គំនូសបង្ហាញ១ បានបង្ហាញពីរចនាសម្ពន្ធ័សមរម្យដែលលោក លោកស្រីគួរតែសិក្សាវគ្គនេះ។លោក លោកស្រីនឹងឃើញថារចនាសម្ព័ន្ធនេះត្រូវបានអនុវត្តតាមគេហទំព័រនៃវគ្គសិក្សារបស់លោក លោកស្រី។គំនូសបង្ហាញ១ក៏បង្ហាញនូវការចាប់ផ្តើមសិក្សារបស់លោក លោកស្រីផ្នែកទី១នៃវគ្គ។

បន្ទាប់ពីយើងបានផ្តល់នូវអនុសាសន៍សម្រាប់លោក លោកស្រីសិក្សាម៉ូលឌុលជាលំដាប់លំដោយដែលម៉ូលឌុលនីមួយៗត្រូវបានបង្ហាញនៅលើអេក្រង់។ តួយ៉ាងដូចជាលោក លោកស្រី គួរតែសិក្សាសិទ្ធិអ្នកនិពន្ធមុនសិទ្ធិប្រហាក់ប្រហែល។ សិទ្ធិប្រហាក់ប្រហែល ត្រូវបានសរសេរ និងសន្មតថាលោក លោកស្រីបានសិក្សាម៉ូលឌុលសិទ្ធិអ្នកនិពន្ធជាមុន។សិទ្ធិសញ្ញាចុះបញ្ជីរបស់អង្គការកម្មសិទ្ធិបញ្ញាពិភពលោក(WIPO)គួរតែជាម៉ូលឌុលចុងក្រោយដែលលោក លោកស្រីត្រូវតែបំពេញមុនពេលបន្តទៅផ្នែកទី៣នៃវគ្គ។នៅផ្នែកទី៣រួមមាន ៖ ការពិភាក្សា និងសង្ខេបវគ្គដែលគួរតែត្រូវបំពេញមុនពេល លោក លោកស្រីប្រលងបញ្ចប់ ។

គ្រប់ម៉ូលឌុលទាំងអស់ផ្តើមពីផ្នែកទី២នៃវគ្គ មានការប្រលងជាសំណួរជាច្រើនជ្រើសរើស មុនបញ្ចប់នៃម៉ូលឌុល។ លោក លោកស្រី នឹងឃើញសញ្ញាសម្រាប់ការប្រលងនេះនៅខាងលើនៃអត្ថបទរបស់ម៉ូលឌុល ។ពិន្ទុ(កំណត់ចំណាំ) របស់លោក លោកស្រីសម្រាប់ការប្រលងនេះនឹងត្រូវបានបង្ហាញដោយស្វ័យប្រវត្តិនៅលើអេក្រង់នៅពេលដែលលោក លោកស្រីបានបំពេញនៃវគ្គសិក្សា។សូមកត់ចំណាំថាការប្រលងនៅចុងបញ្ចប់នៃម៉ូលឌុលគឺគ្រាន់តែជាការសាកល្បងថា លោក លោកស្រីបានយល់នូវអត្ថបទនៃម៉ូលឌុល ដែលលោក លោកស្រីបានអានទេ ។ ពិន្ទុ (កំណត់ចំណាំ) របស់លោក លោកស្រី មិនមែនជាការកំណត់ជាចំណាត់ថ្នាក់ចុងក្រោយនេះទេ ហើយការប្រលងនេះ មិនមានលក្ខណៈជាការបង្ខំគ្រប់ការប្រលងមុនបញ្ចប់នៃម៉ូលឌុលទាំងអស់ទេ។ លោក លោកស្រីអាចប្រលងក៏បានមិនប្រលងក៏បាន។ ហើយការប្រលងបញ្ចប់ (ប្រលងបញ្ចប់វគ្គ) ក៏ជាចម្លើយជ្រើលរើសដែរ។ សូមអានផ្នែកប្រលងបញ្ចប់ខាងក្រោម។

លទ្ធផលនៃការប្រលងរបស់ លោក លោកស្រី នឹងធ្វើការសរុបភ្លាមៗតាមប្រព័ន្ធគ្រប់គ្រងការសិក្សា (LMS)។ នៅពេលដែលលោក លោកស្រី បានសិក្សាគ្រប់ម៉ូលឌុលទាំងអស់ហើយការប្រលងបញ្ចប់របស់លោក លោកស្រី នឹងអាចទទួលបានវិញ្ញាបនបត្រពីអង្គការកម្មសិទ្ធិបញ្ញាពិភពលោក (WIPO) សម្រាប់លោក លោកស្រី ដែលបានសិក្សាវគ្គនេះចប់និងជាប់ជាស្ថាពរ។សូមបញ្ជាក់ថា ចំណាត់ថ្នាក់របស់លោកលោកស្រីមិនមាននៅលើ

©WIPO/OMPI

វិញ្ញាបនបត្រឡើយ។សិក្ខាកាមទាំងអស់តម្រូវឲ្យចូលរកចំណាត់ថ្នាក់របស់ខ្លួនផ្ទាល់ និងថតចម្លងបាន។

©WIPO/OMPI

## វគ្គសិក្សា

វគ្គនេះតម្រូវឲ្យលោក លោកស្រីសិក្សាតាមរយៈប្រព័ន្ធកុំព្យូទ័រ ហើយក៏តម្រូវឲ្យលោក លោកស្រីអានអត្ថបទនិងដ្យាក្រាមនៅលើអេក្រង់ដែលមានសំណួរ ចម្លើយនិងស្តាប់ការថតសម្លេងជាពិសេស។ការស្តាប់សម្លេងគឺជាគុណសម្បត្តិយ៉ាងពិសេសដែលបានចែងនៅក្នុងអត្ថបទនេះ ។ ការស្តាប់សម្លេងមានមូលហេតុពីរគឺ :

- កាត់បន្ថយចំនួនរបស់អត្ថបទដែលលោក លោកស្រីត្រូវអាននៅលើអេក្រង់ ។
- ផ្តល់នូវមធ្យោបាយសមរម្យមួយទៀត សម្រាប់ការជាសិក្សារបស់លោក លោកស្រីដើម្បីបង្កើននូវការចងចាំអត្ថបទ ។

ជាសំណូមពរពេលលោក លោកស្រីឈានដល់វគ្គស្តាប់សំលេងលោក លោកស្រីគួរតែស្តាប់យ៉ាងតិចណាស់ពីរដងមុននឹងចាប់ផ្តើមបន្តទៅមុខទៀត។ លោក លោកស្រីក៏អាចមើលអត្ថបទបាន ប្រសិនមានកន្លែងណាមួយដែលមិនច្បាស់លាស់ ឬ ក៏លោក លោកស្រីពិបាកនឹងស្តាប់សម្លេង ។

ប្រសិនបើលោក លោកស្រីពិតជាចាំបាច់មើលអត្ថបទមែន តែសូមកុំព្យាយាមមើលអត្ថបទ នៅពេលលោក លោកស្រីកំពុងស្តាប់សំម្លេងពីព្រោះវានឹងនាំឲ្យមានការកាត់បន្ថយឥទ្ធិពលនៃសម្លេង និងអាចរំខានដល់ការផ្តោតអារម្មណ៍របស់លោក លោកស្រី ។

គ្រប់ផ្នែកនីមួយៗនៃវគ្គសិក្សានេះ គឺត្រូវភ្ជាប់ជាមួយតារាងកម្មវត្ថុនៃអត្ថបទសិក្សា (Learning objective)ដែលលម្អិតពីចំណេះដឹង ដែលលោក លោកស្រីទទួលបានបន្ទាប់ពីលោក លោកស្រី សិក្សានៃផ្នែកនេះ។ការអានតារាងអត្ថបទសិក្សាដំបូងគេនឹងផ្តល់ឲ្យនូវគំនិតសម្រាប់លោក លោកស្រីដឹងពីអ្វីដែលអ្នកកំពុងសិក្សាដោយខ្លួនឯងផ្ទាល់ ហើយអានផ្នែកនីមួយៗនេះម្តងទៀតនៅចុងបញ្ចប់នៃម៉ូឌុលដើម្បីឲ្យលោក លោកស្រីសម្រេចបាននូវទិសដៅទាំងនេះ។

ដើម្បីជួយលោក លោកស្រី សាកល្បងនូវភាពវិវត្តន៍របស់ខ្លួន លោក លោកស្រី នឹងឃើញសំណួរស្វ័យសិក្សា(SQA) តាមចំណុចផ្សេងនៅក្នុងអត្ថបទ។ សំណួរទាំងនេះ អាចជួយឲ្យប្រាកដថាលោក លោកស្រី បានយល់នូវការពន្យល់ពីតារាងអត្ថបទសិក្សា។ នៅពេលដែលលោក លោកស្រីជួបប្រទះនូវសំណួរស្វ័យសិក្សា លោក លោកស្រីនឹងត្រូវកត់ត្រាចម្លើយនៅលើកុំព្យូទ័រ ។

©WIPO/OMPI

លោក លោកស្រីគួរតែសាកល្បងធ្វើដូច្នេះ មុនពេលលោក លោកស្រីមើលដំណោះស្រាយ។ទាំងនេះគឺជាការបញ្ជាក់នូវតម្លៃថារាល់សំណួរស្វ័យសិក្សា(SQA) គឺសម្រាប់ការប្រើប្រាស់ដោយផ្ទាល់របស់លោក លោកស្រីដោយចម្លើយទាំងនេះគឺត្រូវបានមើលឃើញសម្រាប់តែបុគ្គលផ្ទាល់ខ្លួនឯងតែប៉ុណ្ណោះ។

ពួកយើខំប្រឹងរៀបចំឯកសារទាំងអស់ឲ្យងាយយល់តាមតែអាចធ្វើទៅបាន ប៉ុន្តែវាគឺជៀសមិនរួចទេដែលលោក លោកស្រីនឹងជួបផ្នែកមួយចំនួនដែលពិបាកយល់ជាងផ្នែកផ្សេងទៀត ហើយមិនតែប៉ុណ្ណោះលោក លោកស្រីអាចត្រូវការជំនួយបន្ថែម។ការសិក្សានេះគឺផ្តល់នូវសេវាគាំពារដើម្បីជួយ លោក លោកស្រី ។

នៅក្នុងអំឡុងពេលសិក្សានៃវគ្គនេះលោក លោកស្រីនឹងតម្រូវឲ្យផ្ញើសំណួររបស់លោក លោកស្រីតាមរយៈអ៊ីម៉ែលទៅកាន់ផ្នែករដ្ឋបាលនៃវគ្គសិក្សា (DL101e.academy@wipo.int) ។ រាល់សំណួររបស់លោក លោកស្រីទាំងអស់នឹងត្រូវបានឆ្លើយតបវិញក្នុងរង្វង់ប្រហែលជាពីរ ឬបីថ្ងៃក្រោយមក។

សូមបញ្ជាក់ថាប្រសិនបើការភ្ជាប់អ៊ិធឺណែត មានកម្រិតឃឺតលោក លោកស្រីអាចបោះពុម្ពនូវមាតិកានៃវគ្គដោយចុចភ្ជាប់លើ PDF ដែលមាននៅក្រោមលេខរៀងទំព័រនៃម៉ូឌុលនីមួយៗបាន។

©WIPO/OMPI

## ការប្រលងបញ្ចប់

ប្រមាណជារយៈពេលមួយសប្តាហ៍មុនថ្ងៃកំណត់ពេលចុងក្រោយនៃការបញ្ចប់វគ្គ លោក លោកស្រី នឹងបានភ្ជាប់ទំនាក់ទំនងដោយយកចិត្តទុកដាក់តាមរយៈបែបបទសម្រាប់ដំណើរការប្រលងបញ្ចប់ ។ សូមចងចាំថាការប្រលងរបស់លោក លោកស្រី មានជាទម្រង់ជាសំណួរជ្រើសរើសផ្សេងៗ ហើយនឹងត្រូវបានកំណត់រយៈពេលក្នុងការពិនិត្យនៃការប្រលង។ ការប្រលងបញ្ចប់នេះ គឺមិនដូចជាការប្រលងនៅគ្រប់ចុងវគ្គនៃម៉ូលឌុលនីមួយៗឡើយ គឺលោក លោកស្រីអាចធ្វើការប្រលងនេះបានតែមួយម្តងគត់ ពោលគឺលោក លោកស្រីមិនអាចប្រលងឡើងវិញទេ ប្រសិនបើពិន្ទុរបស់លោក លោកស្រីមិនអាចទទួលបាននូវពិន្ទុ (៥០/១០០) នោះទេ ។ ពិន្ទុប្រលងបញ្ចប់នឹងត្រូវបានគណនាតាមរយៈប្រព័ន្ធគ្រប់គ្រងការរៀនសូត្រ(LMS) ហើយនឹងត្រូវបង្ហាញនៅលើអេក្រង់ភ្លាមៗបន្ទាប់ពីលោក លោកស្រីធ្វើនូវការប្រលងបញ្ចប់ ។ បើសិនការប្រលងបញ្ចប់ដោយជោគជ័យនោះ លោក លោកស្រីនឹងទទួលបាននូវវិញ្ញាបនបត្រ ។

©WIPO/OMPI

## ឧបករណ៍សិក្សានៅក្នុងគេហទំព័រ

បន្ថែមពីនេះទៀតគ្រប់ម៉ូឌុលក្នុងវគ្គ មានគេហទំព័រផ្ទុកទៅដោយឧបករណ៍មួយចំនួនដើម្បីជាជំនួយដល់ការសិក្សារបស់លោក លោកស្រី រួមមាន ៖

- **សទ្ទានុក្រម** ដែលកំណត់នូវរាល់អត្ថន័យនៃពាក្យសំខាន់ៗ ដែលបានប្រើនៅក្នុងវគ្គសិក្សា។ លោក លោកស្រីអាចប្រឹក្សាយោបល់បានគ្រប់ពេល ដោយគ្រាន់តែចុចលើប្រអប់សទ្ទានុក្រម ។

- **អត្ថបទដែលបានប្រើប្រាស់ នៃអត្ថបទច្បាប់ និងបណ្ដាញ** ដែលទាក់ទងនឹងវគ្គនេះ។ អត្ថបទនេះគឺមានអត្ថបទសន្ធិសញ្ញាដែលមានចែងនៅក្នុងវគ្គសិក្សានេះ។សន្ធិសញ្ញាទាំងនេះ អាចត្រូវបានបោះពុម្ព ប្រសិនបើមានសំណូមពរពីលោក លោកស្រី ។

- **សៀវភៅកត់ត្រា**(Grade Book facility): នៅពេលដែលលោក លោកស្រីចុចលើសៀវភៅ លោកលោកស្រី អាចកត់ត្រានៃផ្នែកៗនីមួយៗ ក្នុងវគ្គសិក្សាដែលបានរៀនសូត្ររួច ព្រមទាំងនឹងចម្លើយ នៅគ្រប់ការប្រលងនៃម៉ូឌុលនីមួយៗ ។

- **វេទិកាពិភាក្សាតាមរយៈសារអេឡិចត្រូនិច(អ៊ីម៉ែល)**:
កិច្ចពិភាក្សានឹងអនុញ្ញាតឲ្យលោក លោកស្រីបង្ហាញសំណួរទៅគ្រប់និស្សិតអាហាររូបករណ៍ដែលកំពុងសិក្សាវគ្គនេះដូចលោកលោកស្រីដែរ។ តាមរយៈមុខងារនេះ លោក លោកស្រី ក៏អាចចូលមើលគ្រប់សំណួរ និង ចម្លើយទាំងអស់ដែលត្រូវបានប្តូរក្នុងអំឡុងពេលពិភាក្សា ។

©WIPO/OMPI

# តម្រូវការផ្នែកបច្ចេកវិទ្យា

គេហទំព័រនៅក្នុងវគ្គនេះ គឺបានរចនាឡើងដើម្បីប្រតិបត្តិនូវការប្រើប្រាស់តាមតម្រូវការជាអប្បបរិមា។ សូមចងចាំថាជំនួយបច្ចេកទេសត្រូវបានផ្តល់ដោយរដ្ឋបាលក្នុងវគ្គ (អ្នកគ្រប់គ្រងវគ្គនេះ) ក្នុងករណីដែលលោក លោកស្រីបំពេញបាននូវតម្រូវការទាំងនេះ។

តម្រូវឲ្យមាន**មានកុំព្យូទ័រជាអប្បបរិមា**

**ផ្នែក HardWare :**

Pentiumprocessor or equivalent,233MHz

64MB Ram

28.8K Baud modem or better ( 56.6K Baud modem, Digital Subscriber Line or ISDN connection)

Multimedia capability (specifically a sound card and speakers)

**ផ្នែក Software:**

Windows 95,98, Millennium, NT or 2000

Acrobat Reader

Microsoft Internet Explorer 5 (ឬចុងក្រោយគេបង្អស់)

សមត្ថភាពនៃការផ្ញើសារ ( E-mail)

**សូមចុចចូល:**

Acrobat Reader (free download from www.adobe.com)

Real Player7 (free download from www.realaudio.com)

©WIPO/OMPI